សម្លេងខ្មែរនៅបរទេស

# ឃាតករគ្រប់កាលសម័យ...

ដោយសុទ្ធ-ប៉ូលិន ★ ថ្ងៃទី២០ ធ្នូ ២០០៤

បើយើងសម្លឹងមើលទៅស្តេចសីហនុ ថាជាព្រះបិតាជាតិខ្មែរ ដែលមានប្រជាពលរដ្ឋផ្អើលស្រឡាញ់ភ្លូកទឹកភ្លូកដី យើងមិនអាចយល់បានទេថា ហេតុអ្វីបានជាសីហនុស្តេចទេវរាជរបស់ខ្មែរលើកដាវលំពែងបុកដង្ហើមប្រជាជាតិខ្លួនឯងគ្រប់ពេលសម័យ ។ ក៏ប៉ុន្តែ បើយើងសម្លឹងឃើញស្តេចសីហនុ «ជាតុកត្តាបញ្ចូលរូប» របស់យួនវិញ (ឥតមានវិញ្ញាណរបស់ខ្លួនឯងសោះទេ)... ពោលគឺជា«រូបយួន»សុទ្ធសាធ នោះទើបយើងអាចយល់បាន ពីព្រោះជនជាតិយួនវាតែងបំផ្លិចបំផ្លាញប្រទេសជាតិខ្មែរគ្រប់ពេលសម័យនេះឯង ។

តើគួរដែរឬទេ ដែលនៅក្នុងឆ្នាំ១៩៦៩, ស្តេចសីហនុបានបង្កើតរដ្ឋាភិបាលមួយដឹកនាំដោយសម្តេចប៉ែន-នុត មានឈ្មោះថា «រដ្ឋាភិបាលនៃព្រេងសំណាងចុងក្រោយ» (ពោលគឺជិតអស់ផ្លូវហើយ ?) គឺជារដ្ឋាភិបាលមួយ ដែលតាមកម្ទេចព្យាបាទបណ្តាញពួកបញ្ញាជនខ្មែរក្រហមយ៉ាងសាហាវឃោរឃៅអស្ចារ្យ ។ លោកវ័ណ្ណ-មូលីវ័ណ្ណ ក្មួយរបស់ឯ.ឧ.ប៉ែននុត ដែលមាននាទីជារដ្ឋមន្ត្រីក្រសួងសិក្សាធិការ បានធ្វើសេចក្តីរាយការណ៍ចោទពួកគ្រូបង្រៀនខាងឆ្វេង ហើយផ្ញើប្រគល់ទៅឲ្យក្រសួងប៉ូលិសគិញ ។ ខ្ញុំបានឃើញផ្ទាល់ភ្នែក ទាំងកណ្តាលថ្ងៃត្រង់ ឃើញពួកប៉ូលិសសម្ងាត់របស់សុស្តែន-ហ្វែរណង់ដេស តាមបាញ់ប្រហារពួកបុគ្គលិកសិក្សា ដែលគេចោទថាជា «ពួកខ្មែរក្រហម» រហូតដល់កណ្តាលផ្សារស្មនថ្មី ។ នៅពេលជាមួយគ្នានោះ (មករា១៩៦៨) ឯ.ឧ.សឺន-សាន ក្នុងឋានៈជារដ្ឋមន្ត្រីការបរទេស កំពុងចរចាជាមួយរដ្ឋទូតអាមេរិកាំង (ប្រចាំប្រទេសកម្ពុជា) Chester Bowles ក្នុងប្រការរៀបចំដាក់ចំណងទូតឡើងវិញរវាងកម្ពុជានិងសហរដ្ឋ (សកម្មភាពមួយដែលស្តេចសីហនុ យកទៅលាបមាត់លោកលន់-នល់ដែលឥតដឹងខ្លួនសោះ ដោយចោទថាលោកលន់នល់ក្បត់ជាតិចូលដៃជាមួយអាមេរិកាំង) ។

នៅឆ្នាំ១៩៦៩, ស្តេចសីហនុស្រាប់តែបញ្ចប់សកម្មភាពរបស់លោកប៉ែន-នុត ដោយទៅបង្កើត «រដ្ឋាភិបាលខាងស្តាំមួយ» របស់ឧត្តមសេនិយលន់-នល់ ដែលមានឈ្មោះថា «រដ្ឋាភិបាលស្រោចស្រង់ជាតិ» ព្រោះមានភារកិច្ចដេញយៀកកុងចេញពីដីខ្មែរ ។ ស្តេចសីហនុបានពោលប្រាប់បារាំង Pierre MAX ថា ៖ «ជាការងាយស្រួលណាស់... ដេញយៀកកុងដោយប្រើតែដៃទទេក៏បានដែរ» ពីព្រោះគាត់ធ្លាប់ច្បាំងដេញយៀកមិញម្តងរួចហើយ ដោយប្រើ «កាំភ្លើងឈើ» ។

នៅខែមិនា១៩៧០, ស្រាប់តែស្តេចសីហនុដដែល ជាមួយឯ.ឧ.ប៉ែននុតដដែល (ដែលធ្លាប់សម្លាប់ពួកខ្មែរក្រហមយ៉ាងឃោរឃៅ) បានរត់បោលទៅទីក្រុងប៉េកាំង ដើម្បីទៅបង្កើតរដ្ឋាភិបាលនិងរណសិរ្សខ្មែរក្រហមមួយវិញ... នៅក្រោមឃ្លៀកលោកប្រធានម៉ៅតែម្តង ក្នុងប្រការលើកទ័ពមកសម្លាប់ពួករដ្ឋាភិបាលលន់នល់-សិរិមត: ដែល«ស៊ីដុល្លារអាមេរិកាំង» ។ ដូច្នេះស្តេចសីហនុនេះមិនមែនជា«ស្តេចខ្មែរ»ទេ គឺជា«ស្តេចយួន» ពីព្រោះស្តេចអង្គនេះបានលាបពណ៌ឲ្យខ្មែរសម្លាប់គ្នា ដូចគេក្តិចស្រមោចសង្គ្រារប្រជល់គ្នា ទាល់តែខ្មែរស្លាប់ផុតពូជ ។

❑

## យួននិងសីហនុ ជាអ្នកជំរុញប៉ុល-ពត ឲ្យពិឃាតលោកហ៊ូ-នឹម ៖

តទៅនេះជាអត្ថបទមួយដកស្រង់ពីសៀវភៅ «បងប្អូនខ្មាំងសត្រូវ» (Brother Ennemy)របស់លោក Nayan Chanda -pages 104-105) ៖

[ «ពេលវេលាបន្តិចបន្តួច ដែលសីហនុបានអង្គុយជាមួយខៀវ-សំផន, ជាមួយរដ្ឋមន្ត្រីការបរទេសអៀង-សារី ឬក៏ជាមួយរដ្ឋមន្ត្រីក្រសួងឃោ-សនាការហ៊ូ-នឹម, ពួកគេគ្រាន់តែបានស្តាប់ទ្រង់ដោយការគួរសមតែប៉ុ-ណ្ណោះឯង ប៉ុន្តែពួកគេមិនដែលធ្វើតាមទ្រង់ម្តងណាឡើយ ។ «ម្តេចបានជាមិនអនុញ្ញាតឲ្យពួកសកម្មការងារនៅក្នុងសហករ បានទទួលការឈប់សំរាកនៅថ្ងៃអាទិត្យផងទៅ?», ពួកគេតែងតែមានចម្លើយដូច្នេះជានិច្ចជាកាលត្រឡប់មកវិញ «យើងមិនអាចបញ្ឈប់ចំណង់ពុះពោររបស់មហា-ជន ដែលស្វះស្វែងបង្កើតភោគផលយ៉ាងខ្ពស់ដល់កម្រិតនោះឡើយ» ។ ដោយមានសេចក្តីទោមនស្សជាខ្លាំង ស្តេចសីហនុក៏ចាប់ផ្តើមធ្វើការតិ-ទៀន (អង្គការប៉ុល-ពត) ដោយសំណើចចំអកពេបជ្រាយ ។

«ពីរ-បីអាទិត្យក្រោយមក បន្ទាប់ពីទ្រង់បានវិលត្រឡប់មកភ្នំពេញវិញ សម្តេចសីហនុបានផ្ញើលិខិតអញ្ជើញ ផាំ-យ៉ាំងបា អគ្គរដ្ឋទូតថ្មីរបស់វៀតណាម (ដែលមកពីខាងត្បូង) មកធ្វើការស្រស់ស្រូបថ្ងៃត្រង់ ។ សេចក្តីអញ្ជើញនេះត្រូវចាត់ទុកថា ជាសំណើចចំអកមួយ ។ ពីព្រោះកាលពីមុននេះថ្មីៗ ជនវៀតណាមមាឌស្តើងតូចម្នាក់នេះ គឺជាភ្នាក់ងារចារកិច្ចរបស់រដ្ឋាភិបាលកុម្មុយនិស្តវៀតណាមនៅភ្នំពេញ ដែលខំប្រឹងរត់គេចពីក្រុមប៉ូលិសរបស់សីហនុ ។ ថ្ងៃក្រោយមក ផាំ-យ៉ាំងបា នេះ បានលេចឡើងជាអ្នកតំណាងរដ្ឋាភិបាលយៀកកុងនៅទីក្រុងបារីស ។ នៅក្នុងពិធីស្រស់ស្រូបភោជនាហារនេះ ក៏មានវត្តមានរបស់ហ៊ូ-នឹមផងដែរ ដែលមានតួនាទីជារដ្ឋមន្ត្រីក្រសួងឃោសនាការនៃរដ្ឋាភិបាលកម្ពុជា ។ ឥស្សរជនចុងក្រោយនេះនៅខំប្រឹងធ្វើបុកខ្លួនឯងជារដ្ឋមន្ត្រីនៃរដ្ឋាភិបាលរួបរួមជាតិ (Grunk) ទៀតផង ។ ផាំ-យ៉ាំងបា ក៏បានផ្តល់កិត្តិយសដល់សីហនុដោយថ្លែងរៀបរាប់អំពីសេចក្តីទុក្ខលំបាក ដែលកើតមានឡើងនៅក្នុងជីវិតពិសោធន៍នៃវៀតណាមខាងត្បូង ពេលដែលបានត្រូវរំដោះរួចហើ-យ ។ «ក៏ប៉ុន្តែប្រទេសកម្ពុជាក៏ដូចនេះដែរ គឺកំពុងតែដើរចូលក្នុងផ្លូវខុស», ពាក្យទាំងនេះជាអន្តរាគមន៍របស់ស្តេចសីហនុ ដែលបណ្តាលឲ្យហ៊ូ-នឹមមានការរសាប់រសល់យ៉ាងខ្លាំង ។ ដូច ផាំ-យ៉ាំងបា បានពន្យល់មកខ្ញុំ (Nayan Chanda) នៅថ្ងៃក្រោយមកដូចនេះឯង, ខ្លួនគេគ្រាន់តែចង់បន្ធូរបន្ថយពាក្យរបស់ស្តេចសីហនុកុំឲ្យមានពិសខ្លាំងពេកតែប៉ុណ្ណោះ ។ «ជាការពិតណាស់» ជនវៀតណាមពោល «ប្រទេសវៀតណាមខាងត្បូងនិងប្រទេសកម្ពុជា គឺជាប្រទេសពីរដែលមានជម្ងឺដូចគ្នា បន្សល់មកពីចក្រពត្តិអាមេរិក ។ ប៉ុន្តែពេលនេះហើយ ដែលគេត្រូវកែរោគនៃប្រទេសទាំងពីរឲ្យបានជាសះស្បើយ» ។ ដោយមិនព្រមចាញ់នឹងពាក្យសំដីបន្ធូរបន្ថយរបស់ផាំ-យ៉ាំងបា... សម្តេច (សីហនុ) ក៏បានឆ្លើយតបវិញថា ៖ «រឿងនេះវាច្បាស់ជាដូច្នេះហើយ ក៏ប៉ុន្តែពួកមេដឹកនាំនៅទីនេះ ហាក់ដូចជាប្រើថ្នាំខ្លាំងជ្រុលពន់ពេក» ។ ពេលនោះក៏ស្រាប់តែមានសេចក្តីស្ងប់ស្ងាត់ជាខ្លាំង ដោយអ្នកទាំងអស់គ្នាមានការទើសទាល់ ។ ផាំ-យ៉ាំងបាក៏សម្លឹងមើលទៅហ៊ូ-នឹម ។ ចំណែកហ៊ូ-នឹមក៏សម្លឹងមើលទៅក្តារ ។ មួយឆ្នាំក្រោយមក ហ៊ូ-នឹមបានត្រូវគេពិឃាត ដោយជាប់ចោទជាភ្នាក់ងារចារកិច្ចរបស់សេអ៊ីអា» ] ។

❑

## ប៉ុល-ពតជំរុញឲ្យសូ-ភឹមពិឃាតជនជាតិចាម៦,000នាក់រួចបង្ខំឲ្យសូ-ភឹមសម្លាប់ខ្លួន, ចំណែកយួនជំរុញឲ្យប៉ុល-ពតធ្វើការពិឃាតរង្គាល

**នៅលើមហាជនទូទៅ... រួចក៏បង្កើតល្បិចកលព្រលំរបបប៉ុល-ពត ដើម្បីឲ្យខ្មែរជំពាក់គុណយួន !!!** ៖

ជាការជាក់ច្បាស់ណាស់ នៅក្រោយការសម្លាប់គ្នារបស់ខ្មែរខាងណាក៏ដោយ ក៏មានយួនដែរ ។ តទៅនេះជាអត្ថបទដកស្រង់ពីសៀវភៅ **Brother Ennemy** របស់លោក **Nayan Chanda** ដដែល ( **Pages 249-250-251** ) ៖

«នៅគ្រប់ជំនាន់ទាំងអស់, ទីកន្លែងដែលប្រកបដោយគ្រោះថ្នាក់បំផុតចំពោះអង្គការដឹកនាំរបស់ប៉ុល-ពត គឺតំបន់ទិសខាងកើត ។ តាំងពីមានកំណើតពួកឥស្សរៈប្រឆាំងនឹងបារាំងនៅក្នុងឆ្នាំ១៩៤០មកម្ល៉េះ, តំបន់នេះមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងពួកវៀតណាមកុម្មុយនិស្ត ។ គឺដោយហេតុថាជាតំបន់ខ្មែរ ដែលនៅជាប់ក្បែរបង្កើយនឹងវៀតណាមផង និងដោយវត្តមាននៃពួកសកម្មការងារវៀតណាមនៅចំការកៅស៊ូជប់នោះផង ជាហេតុឲ្យមានការសំរួលនូវការពាក់ព័ន្ធមេត្រីខាងលើនេះ ។ នៅក្នុងដំណាក់ការដំបូងនៃការតស៊ូប្រឆាំងនឹងរដ្ឋការលន់-នល់ គឺនៅក្នុងតំបន់នេះហើយ ដែលពួកវៀតណាម (កុម្មុយនិស្ត) បានជួយជ្រោមជ្រែងយ៉ាងខ្លាំងក្លា បង្កើតឲ្យមានកងទ័ពខ្មែរតស៊ូរំដោះ ។ ទំនាក់ទំនងដ៏យូរអង្វែងជាមួយនឹងវៀតណាម បានធ្វើឲ្យតំបន់ខាងកើតមានលក្ខណៈជាខ្មែរកុម្មុយនិស្តវៀតណាម (ឬខ្មែរយៀកមិញ) ។ នៅក្នុងពេលជាមួយគ្នានោះ ក្រុមដែលដឹកនាំដោយប៉ុល-ពត ច្រើនតែទទួលឥទ្ធិពលពីចិនម៉ៅ-សេទុង ដែលប្រៀនប្រដៅឲ្យធ្វើសង្គ្រាមតស៊ូរវាងវណ្ណៈនិងវណ្ណៈ, ខុសគ្នានឹងពួកមេដឹកនាំខាងកើតដែលទទួលយក«សង្គមនិយម»នៃការកែប្រែបន្តិចម្តងៗ» របស់វៀតណាម ។ សង្គមនិយមនេះ ជំរុញឲ្យមានសហការ ទោះជាមួយពួកអភិជនក៏ដោយ ដើម្បីបង្កើតភោគផល ។ ទំនាស់រវាងវណ្ណៈនិងវណ្ណៈជារឿងបន្ទាប់បន្សំ សំរាប់ដោះស្រាយនៅពេលក្រោយប៉ុណ្ណោះវិញ ។

«គេមិនអាចដឹងបានទេថា តើពួកមេដឹកនាំខាងកើតបានប្រឆាំងនឹងនយោបាយប៉ុល-ពតដល់កម្រិតណាទេ ។ គេគ្រាន់តែដឹងថា ពួកទាំងនេះបែបដូចជាមិនសូវសប្បាយចិត្តនឹងទ្រឹស្តីឆ្វេងនិយមជ្រុល និងការអនុវត្តន៍នយោបាយដ៏តឹងរ៉ឹងតក្កហលហួសប្រមាណរបស់អង្គការកណ្តាល (ប៉ុល-ពត) ។ នៅក្នុងរយៈពេល៣ឆ្នាំដំបូងនៃបដិវត្តន៍ខ្មែរក្រហម តំបន់នេះមានចំណីចំណុកម្ហូបអាហារបរិបូណ៌ ចំណែក«ពួកប្រជាជនថ្មី» (ដែលជន្លៀសមកពីទីក្រុង) ក៏រស់នៅបានសុខស្រួលផងដែរ គឺមិនធ្ងន់ធ្ងរដូចតំបន់ផ្សេងៗទៀតនៃកម្ពុជាប្រជាធិបតេយ្យនោះឡើយ ។

«ទាំងនេះពុំមែនមានន័យថា នៅតំបន់ខាងកើតពុំមានការសម្លាប់រង្គាលនោះទេ ។ ចំនួនពួកជនជាតិចាម (ភាគតិច) ប្រមាណជា៦,០០០នាក់ ជាពិសេសនៅខេត្តកំពង់ចាម ត្រូវបានរងគ្រោះដោយការកាប់សម្លាប់យ៉ាងឃោរឃៅ ពីព្រោះតែពួកអ្នកទាំងនេះមានជំនឿទៅលើលទ្ធិសាសនាអ៊ិស្លាម ។ ពួកជនជាតិយួនស៊ីវិល ក៏បានទទួលការពិឃាតយ៉ាងព្រៃផ្សៃផងដែរ ដែលជាស្នាដៃរបស់ពួកកុម្មង់ដូឃាតករនៅតំបន់ខាងកើត ដែលបានទទួលការជំរុញនិងលើកទឹកចិត្តពីអង្គការកណ្តាល (ប៉ុល-ពត) ដូចគ្នា ។ ទោះជាយ៉ាងនេះក៏ដោយ ពួកក្របខណ្ឌខ្មែរក្រហមដ៏ច្រើនបំផុត ដែលងើបឡើងប្រឆាំងនឹងអំពើឆ្កួតលីលារបស់ប៉ុល-ពត គឺស្ថិតនៅតំបន់ខាងកើត ។ ហើយពួកទាំងនេះឯង ដែលអង្គការប៉ុល-ពតបានពិឃាតចោលយ៉ាងច្រើនសន្ធឹកសន្ធាប់ជាបំផុតដែរ ពោលគឺរកតែពួកគេធ្វើអ្វីមិនកើត» ។

**«ពួកក្បាលយួន-ខ្លួនខ្មែរ»**

«យើងបានឃើញរួចហើយនូវកង្វះសមត្ថភាពនៃកងទ័ពតំបន់ខាងកើត ក្នុងប្រការទប់ទល់នឹងការលុកលុយរបស់វៀតណាម ក្នុងខែធ្នូ១៩៧៧ ដែលជាហេតុបណ្តាលឲ្យមានការចាប់ផ្តើមពិឃាតផ្ទៃក្នុងយ៉ាងសំបើមនៅក្នុងអង្គការខ្មែរក្រហម ។ នៅក្នុងសភាពច្របូកច្របល់វឹកវរ បន្ទាប់ពីទ័ពវៀតណាមដកថយទៅ ពួកកងទ័ពនៅក្នុងតំបន់ ដែលបានរលាយខ្លួនបាត់អស់កាលពេលដែលយួនចូលមក ក៏បែរទៅជាបាញ់ប្រយុទ្ធប្រទ្រុះប្រទ្រះជាមួយនឹងកងទ័ព ដែលអង្គការកណ្តាលទើបបញ្ជូនមកថ្មីៗទៅវិញ ជាហេតុឲ្យកើតមានក្តីសង្ស័យអំពីការឃុបឃិតស៊ីគ្រលុំ (រវាងពួកខាងកើតនិងពួកយួន) ។ ម្ល៉ោះហើយពួកក្របខណ្ឌយោធាថ្នាក់កណ្តាលប្រចាំតំបន់ ព្រមទាំងពួកមជ្ឈឹមបក្សនៅក្នុងកងវរសេនាធំនៃអង្គការកណ្តាលប្រចាំនៅខាងកើត ក៏បានត្រូវកោះហៅម្នាក់ម្តងៗទៅទីក្រុងភ្នំពេញ ដើម្បីទៅធ្វើជំនួប «មេទឹង» ។ ពួកអ្នកទាំងអស់នេះ មិនបានវិលត្រឡប់វិញទេ ។ នៅទួលស្លែង មានឯកសារបញ្ជាក់ពីការចាប់ខ្លួននៃពួកមជ្ឈឹមបក្សមកពីតំបន់ខាងកើតរហូតដល់ទៅ៤០៩នាក់ ។ ពួកមេបញ្ជាការនៃកងពលធំពីរនៃតំបន់ខាងកើត ក៏ត្រូវចាប់ខ្លួនផងដែរ នៅក្នុងខែមេសា១៩៧៧ ។ មេបញ្ជាការម្នាក់ឈ្មោះ ហេង-ថាល់ ត្រូវជាបងរបស់ហេង-សំរិន ជាអ្នកកាន់កងពលធំលេខ២៩០ ។

«នៅថ្ងៃទី១០ ឧសភា វិទ្យុភ្នំពេញក៏បានធ្វើការផ្សាយអំពាវនាវមួយដ៏មហាអស្ចារ្យ គឺឲ្យសម្លាប់ពួកជនជាតិយួនទាំងអស់ ដើម្បីធ្វើការ«សំអាតជួរ»របស់ខ្លួន ឲ្យមានសភាពបរិសុទ្ធ ។ «បើគិតពីចំនួនវិញ យើងម្នាក់ៗត្រូវសម្លាប់យួនឲ្យបាន៣០នាក់ ពោលយើងត្រូវបាត់បង់តែម្នាក់ទេ ដើម្បីទប់ទល់នឹងយួនដែលត្រូវបាត់បង់៣០នាក់ ។ យើងមិនចាំបាច់កេណ្ឌប្រជាជន៨លាននាក់ទៅច្បាំងទេ យើងត្រូវការតែ២លាននាក់ក៏គ្រប់គ្រាន់ហើយ ដើម្បីច្បាំងនឹងយួន៥០លាននាក់, ហើយទោះជាយ៉ាងណាក៏យើងនៅសល់៦លាននាក់ទៀតដែរ ។ ( កកន ៖ សេចក្តីអំពាវនាវរបស់ប៉ុលពតនេះ ធ្វើឲ្យគេនឹករលឹកដល់សេចក្តីអំពាវនាវរបស់ស្តេចសីហនុ មុនថ្ងៃ១៩មិនា១៩៧០ ដែលជំរុញឲ្យកងទ័ពលន់-នល់៣៥,០០០នាក់ ដែលមានតែកាំភ្លើងបាញ់ចេញគ្រាប់ស្អុយ ឲ្យច្បាំងនឹងពួកយៀកកុង២០ម៉ឺននាក់ ប្រដាប់ដោយអាវុធពីក្បាលដល់ចុងជើង ។ នេះជាមធ្យោបាយបំបាត់ពូជខ្មែរទេតើ មិនមែនបំបាត់ពូជយួនទេ ) ។

«គេមានចម្ងល់ថា តើសូ-ភឹមដែលជាសមាជិកម្នាក់នៃអង្គការលើផងដែរ មានបានចូលដៃក្នុងអំពើឆ្កួតលីលានៃការពិឃាតផ្ទៃក្នុងបែបនេះឬទេ ? តាមយោបល់លោក **Ben Kiernan**, អ្នកស្រាវជ្រាវដ៏ល្បីល្បាញម្នាក់នៃប្រវត្តិខ្មែរក្រហម, សូ-ភឹម កាលសម័យនោះមានជម្ងឺសឹងគ្រប់ពេលវេលាទៅហើយៗក៏ពុំបានដឹងអំពីការចាប់ខ្លួននៃពួកមជ្ឈឹមបក្សដែរ ។ នៅពេលដែលគាត់បានដឹងពីប្រការចាប់ខ្លួននៃមេបញ្ជាការកងពលធំប្រចាំនៅខាងកើតពីររូប គឺលេខ២៨០និង២៩០ គាត់ក៏មានកំហឹងពុះពោរជាខ្លាំង ។ ប៉ុន្តែប្រតិកម្មរបស់គាត់មានលក្ខណៈធូរខ្សោយ ដោយគ្រាន់តែស្នើសុំឲ្យអ្នកផង «ធ្វើការប្រុងប្រយ័ត្នឲ្យមែនទែន» ។ យោងតាមលោក **Kiernan**, សូ-ភឹមនេះត្រូវចងខ្លួនជាប់ក្នុងបទវិន័យនិងជំនឿរបស់គាត់ផ្ទាល់ ដែលជឿថាការចាប់ចងនិងការពិឃាតផ្ទៃក្នុង គឺវាជារឿងធម្មតានៃបដិវត្តន៍ ។ នៅពេលចំនួនជនពិឃាតក្នុងបក្សកាន់តែរីកធំឡើង ភូ-ភឹមកាន់តែភ្លឹកភ្លាំងភាំងស្មារតីធ្វើអ្វីលែងកើត ។ ប៉ុន្តែតាមយោបល់របស់លោក **Stephen Heder** វិញ សូ-ភឹមនេះបានចងបក្សជាមួយប៉ុល-ពត (ពេលវៀតណាមដកថយផុតទៅ) ក្នុងប្រការកំចាត់បក្សពួកផ្ទៃក្នុងនៃក្របខណ្ឌយោធា ។ ដើម្បីរស់រានមានជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេត្រូវតែទម្លាក់ទោសកំហុសនិងអំពើក្បត់ទៅពួកថ្នាក់ខាងក្រោម ។

«ប៉ុន្តែយោងតាមលោក **Heder**, សូ-ភឹមមិនបានដឹងថាខ្លួនឯងជាជនជាប់សង្ស័យនោះទេ គឺក្នុងប្រការបានធ្វើឲ្យតំបន់ខាងកើតសំបូរសប្បាយដោយឥវ៉ាន់ហូបចុក ដែលធ្វើឲ្យតំបន់នេះធូរស្រាលក្នុងការរស់នៅ

ហើយបែកឆ្វេងក្នុងការចែកផ្លូវគ្នាដើរ » ។

«ទោះជាយ៉ាងណាក៏ដោយ រឿងសូ-ភឹមខំប្រឹងគេចដោះខ្លួនពីសំណាញ់មរណៈរបស់ប៉ុល-ពត ក៏ក្លាយទៅជារឿងហេតុបណ្ដាលឲ្យផ្ទុះសង្គ្រាមស៊ីវិល រវាងខ្មែរក្រហមហើយនិងខ្មែរក្រហម ដែលចុងចប់ទៅជំរុញឲ្យមានអន្តរាគមន៍យ៉ាងគគ្រឹកគគ្រេងនៃកងទ័ពវៀតណាម ចូលមកក្នុងប្រទេសកម្ពុជា » ។

«នៅចុងខែឧសភា១៩៧៨, កែ-ពោក មេបញ្ជាការកណ្ដាលរបស់ប៉ុល-ពត ក៏បានផ្ញើសេចក្ដីអញ្ជើញទៅសូ-ភឹម ឲ្យមកបង្ហាញខ្លួននៅជំនួប «មេទឹង» ។ សូ-ភឹមដឹងច្បាស់ណាស់អំពីអត្ថន័យនៃសេចក្ដីអញ្ជើញបែបនេះ ។ គាត់បានផ្ញើនិរសារបីនាក់ព្រមទាំងមេដឹកនាំបក្សជាន់ខ្ពស់ម្នាក់ផង ដើម្បីទៅស៊ើបសួរអំពីជំនួប«មេទឹង»នេះ ។ ប៉ុន្តែអ្នកទាំងបីនេះ ពុំបានវិលត្រឡប់វិញទេ » ។

«នៅថ្ងៃទី៨ឧសភា, កងទ័ពបញ្ជាការកណ្ដាលរបស់ប៉ុល-ពតបានទៅព័ទ្ធពួកសេនាធិការនៃតំបន់ខាងកើត នៅស្រុកសួង ចម្ងាយ២០ម៉ែល៍ពីវៀតណាម ។ ពួកមេបក្សជាច្រើនបានត្រូវគេចាប់ចង ហើយបញ្ជូនទៅរកសេចក្ដីស្លាប់ ។ ប៉ុន្តែសូ-ភឹមបានគេចខ្លួនផុតរួចទៅហើយ ដោយឡើងជិះឡានហ្ស៊ីបឆ្ពោះទៅភ្នំពេញ ដោយនាំប្រពន្ធកូនហើយនិងអង្គរក្សរបស់គាត់ទៅផង ។ គាត់បានប្រាប់កូនចៅរបស់គាត់ថា កែ-ពោកហើយនិងរដ្ឋមន្ត្រីការពារប្រទេស សុន-សេន ជាក្រុមក្បត់ គឺបានដឹកនាំការសម្លាប់ផ្ដែក្នុងបក្សនេះដោយចិត្តឯង ។ ម្ល៉ោះហើយ គាត់ចង់ទៅប្រាប់អង្គការកំពូលប៉ុល-ពតនោះ ឲ្យបានជ្រាបនូវពត៌មាននេះ ។ គាត់មិនទាន់ដឹងខ្លួនទេថា នៅក្នុងភ្នែករបស់ប៉ុល-ពត គាត់នេះជាជនក្បត់នៅទិសខាងកើតរួចទៅហើយ ជាមេបក្សបន្លំខ្លួន បញ្ជូនមកដោយពួកវៀតណាមនិងពួកសេអ៊ីអា ឲ្យមកដណ្ដើមកាន់កាប់អំណាចនៅកម្ពុជា » ។

សូ-ភឹមក៏ទៅតាំងខ្លួន នៅដីកោះមួយកណ្ដាលទន្លេមេគង្គ ក្បែរភ្នំពេញ ហើយរង់ចាំដំណឹងពីប៉ុល-ពត ។ (គាត់បានបញ្ជូននិរសាម្នាក់ទៀតទៅជួបប៉ុល-ពត មុននឹងគាត់ចូលរដ្ឋធានី) ។ នៅថ្ងៃទី២មិថុនា ប៉ុល-ពតបានបញ្ជូនសាឡាង (នាវាចម្លង) ពីរពោរពេញដោយយោធា ដោយមានដាក់បដា «ស្វាគមន៍» សំរាប់ទទួលសមមិត្តសូ-ភឹម ។ គាត់នេះយល់ច្បាស់ណាស់ ថាគាត់មានដំណើរមកដល់ដំណាក់ការចុងក្រោយរួចហើយ ។ សូ-ភឹម ក៏បានដកកាំភ្លើងពីស្ពាយឡេត៍ បាញ់ប្រហារខ្លួនឯងចំកណ្ដាលដើមទ្រូងទៅហោង » ។៚